**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Sep-2015, 09:08
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ** អមដោយ **ឧបសម្ព័ន្ធ ក សម្ងាត់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រ និងសុំដាក់ចម្លើយតបតែមួយភាសា នៅនឹងសំណើសុំភស្តុតាងបន្ថែមលើកទីប្រាំមួយរបស់ នួន ជា**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម A. KLONOWIECKA- MILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Florence NUMBA
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Anta GUISSÉ
លោក Arthur VERCKEN

# I. សេចក្តីផ្តើម

1. អនុលោមតាមមាត្រា ៥.៤ និង ៧.២ នៃសេចក្តីណែនាំអនុវត្តដែលពាក់ព័ន្ធ[1] សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”) ផ្តល់ការអនុញ្ញាតបន្ថែមចំនួន ១៥ ទំព័រ សម្រាប់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើសុំភ័ស្តុតាងបន្ថែមលើកទីប្រាំមួយរបស់ នួន ជា (សំណើរបស់ នួន ជា”[2]) និងការអនុញ្ញាតដាក់តែមួយភាសាអង់គ្លេសជាមុនសិន ដោយសំណៅបកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន។

# II. សេចក្តីសន្និដ្ឋាន

2. ចំនួនទំព័របន្ថែម និងការអនុញ្ញាតដាក់ជាភាសាអង់គ្លេសជាដំបូងដែលត្រូវបានស្នើសុំនេះ ត្រូវបានផ្តល់យុត្តិកម្មផ្អែកតាមកាលៈទេសៈលើកលែង។ ទីមួយ មិនមានជម្រើសបកប្រែភាសាណាមួយដែលអាចរកបានសម្រាប់សហព្រះរាជអាជ្ញា ដែលអនុញ្ញាតឱ្យចម្លើយតបទៅនឹងសំណើរបស់ នួន ជា អាចត្រូវបានបកប្រែមុនកាលបរិច្ឆេទកំណត់ដាក់ឯកសារឡើយ។ ចម្លើយតបនេះត្រូវផុតកំណត់នៃការដាក់នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ ដោយរាប់យកថ្ងៃទីមួយនៃថ្ងៃដាក់ឯកសារបន្ទាប់ពី១៥ថ្ងៃនៃថ្ងៃប្រក្រតិទិននៃការជូនដំណឹងនៃសំណើសុំរបស់ នួន ជា ជាពីរភាសា[3]។ ទោះបីជាសហព្រះរាជអាជ្ញាព្យាយាមឱ្យមានការបកប្រែឯកសារនានានៅក្នុងការិយាល័យរបស់ខ្លួនដើម្បីសម្រួលដល់បន្ទុកផ្នែកគ្រប់គ្រងតុលាការ (“CMS”) ក៏ដោយ ក៏ការព្យាយាមនេះមិនអាចធ្វើទៅបានទេចំពោះចម្លើយតបមួយនេះ ដោយសារតែអ្នកបកប្រែនៅ កសព ជាប់មមាញឹកក្នុងការបកប្រែសារណាផ្សេងៗទៀត។ ហេតុដូច្នេះ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាបានទាក់ទងទៅ CMS ដើម្បីសាកសួរថាតើចម្លើយតបនេះអាចត្រូវបានបកប្រែជាភាសាខ្មែរ

[1] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, អវតក/០១/២០០៧/វិសោធនកម្មលើកទី៨, ៧ មីនា ២០១២។

[2] **F2/8** សំណើលើកទី ៦ របស់ នួន ជា ស្នើសុំឱ្យមានការពិចារណា និងទទួលយកភ័ស្តុតាងបន្ថែមទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១, ១១ កញ្ញា ២០១៥។

[3] វិធាន១០៨(៧) នៃវិធានផ្ទៃក្នុង (វិ.៨) ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១។

មុនកាលបរិច្ឆេទកំណត់ដាក់ឯកសារឬទេ។ ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធ ក[4] CMS បានបញ្ជាក់ថា ខ្លួនមិនមានលទ្ធភាពធ្វើបានទេ។

*3.* ទីពីរ ចំនួនទំព័របន្ថែម គឺជាការចាំបាច់ដើម្បីឆ្លើយតបឲ្យបានគ្រប់គ្រាន់ទៅនឹងសំណើរបស់ នួន ជា គឺចំនួន ៦០(ហុកសិប)ទំព័រ - ដែលត្រូវបានអនុញ្ញាតឲ្យមានការបន្ថែមទ្វេដងទៅនឹងចំនួនទំព័រធម្មតាដែលបានកំណត់ជាធរមាន[5]។ វាគឺជាសំណើសុំភស្តុតាងបន្ថែមលើកទីប្រាំមួយរបស់ នួន ជា នៅក្នុងបណ្តឹងសាទុក្ខ និងត្រូវបានរៀបរាប់ដោយមេធាវីការពារក្តី នួន ជា ថា “យើងខ្ញុំក៏ស្នើសុំឲ្យមានធនធានដើម្បីឲ្យយើងខ្ញុំអាចសរសេរនូវសំណើទាំងនេះបាន”[6]។ ដោយការទទួលស្គាល់ដោយខ្លួនឯង នួន ជា បានបញ្ចូលគ្នានូវអ្វីដែលធ្លាប់ជាសំណើសុំភស្តុតាងបន្ថែមដាច់ៗ ពីគ្នាចំនួន ០៣(បី) (ដែលទៅតាមវិធានផ្ទៃក្នុង នឹងត្រូវផ្តល់ជូនចំនួន ៩០(កៅសិប)ទំព័រ ឲ្យទៅសហព្រះរាជអាជ្ញាដើម្បីធ្វើការឆ្លើយតប) ឲ្យទៅជាសំណើសុំតែមួយ[7]។ ដូច្នេះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ការណ៍នេះដែលបណ្តាលឲ្យមានការបន្ថែមចំនួនទំព័រត្រូវបានបង្កើតឡើង គឺដោយសារតែវិសាលភាពនៃសំណើរបស់ នួន ជា និងភាពចាំបាច់ក្នុងការឆ្លើយតបឲ្យបានត្រឹមត្រូវទៅនឹងសំណើនោះ។ ទោះបីជា នួន ជា បានស្នើសុំ និងបានទទួលទ្វេដងទៅនឹងចំនួនទំព័រធម្មតា ដែលបានកំណត់ជាធរមានក៏ដោយ ក៏សហព្រះរាជអាជ្ញាបានកម្រិតខ្លួនឯងចំពោះសំណើមួយ សម្រាប់យ៉ាងច្រើនតែពាក់កណ្តាលប៉ុណ្ណោះ។

## III. សេចក្តីសន្និដ្ឋាន

ដូចមូលហេតុដែលបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះអនុញ្ញាតបន្ថែមចំនួន ១៥ ទំព័រ និងអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបរបស់ខ្លួនតែមួយភាសា

---

[4] អ៊ីមែលពីការិយាល័យសហព្រះរាជអាជ្ញាទៅកាន់ CMS ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥។

[5] **F27/1** សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រសម្រាប់សំណើទីប្រាំមួយស្តីពីការ ដាក់ភស្តុតាងបន្ថែមដែលនឹងស្នើឡើងនៅពេលខាងមុខ, ១៧ សីហា ២០១៥។

[6] **E1/349.1** ត្រង់ 01148631, បន្ទាត់ 12-17។ មេធាវីការពារក្តី នួន ជា ក៏បានរៀបរាប់ផងដែរពីសំណើថាជា “សំណើសុំសំខាន់ចាប់ តាំងពីឆ្នាំ២០០៨ មក ជាមួយនឹងតុលាការកំពូល”។

[7] **F27** សំណើបន្ទាន់របស់ នួន ជា ស្នើសុំចំនួនទំព័របន្ថែមសម្រាប់សំណើលើកទី៦ របស់ខ្លួនសុំឲ្យទទួលយកភស្តុតាងបន្ថែមសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០១, ១២ សីហា ២០១៥, កថាខណ្ឌ៤,៦។

អង់គ្លេសជាមុនសិន ដោយសំណៅបកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | |